00281320

**Declassified to Public**
**06 September 2012**

E2/89/3

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 02 / 2009
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

---------------

# សេចក្តីបញ្ជាក់បន្ថែមលើសំណើរសុំវិធានការការពារ លើអ្នកដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កញ្ញា អ៊ុក នារី

នាងខ្ញុំ មេធាវី **ម៉ុច សុវណ្ណារី** ជាមេធាវីតំណាងដោយអាណត្តិរបស់កញ្ញា **អ៊ុក នារី** (អ្នកដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី) នៅក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ស.ជ។

**សូមគោរពចូលមកលោកប្រធានអង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

*សូមមានជ្រាប។*

**កម្មវត្ថុ ÷** សំណើរផ្តល់សេចក្តីបញ្ជាក់បន្ថែមលើពាក្យសុំវិធានការការពារ របស់អ្នកដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កញ្ញា **អ៊ុក នារី**

**យោង ÷** (១) ពាក្យស្នើសុំវិធានការការពារលើរូបកញ្ញា **អ៊ុក នារី** ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៩

(២) មាត្រា ៣.១ ចំណុច ឃ នៃសេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០៣/២០០៧/វ០១ ស្តីពីវិធានការការពារ

តបតាមកម្មវត្ថុ និងយោងខាងលើ ដោយបន្ថែមលើវិធាន២៩ (៤) ខ នាងខ្ញុំសូមស្នើដកចេញនូវរាល់កំណត់ហេតុទាំងឡាយចេញពីសំណុំរឿង ដែលអោយគេស្គាល់នូវអត្តសញ្ញាណរបស់ កញ្ញា **អ៊ុក នារី** ជាបុគ្គលដែលត្រូវការពារ ឬព័ត៌មានផ្សេងទៀត ដែលអាចបង្ហាញអំពីអត្តសញ្ញាណឬទីកន្លែងរបស់គាត់។ នាងខ្ញុំស្នើសុំវិធានការពារនេះ ដោយមានការបិទបាំងអត្តសញ្ញាណឬទីកន្លែងរបស់គាត់ពីគ្រប់ភាគីទាំងអស់ រួមបញ្ចូលទាំងសាធារណៈជនផងដែរ។

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 10 / 02 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

00281321

E2/89/3

អាស្រ័យហេតុដូចបានជំរាបជូនខាងលើ សូមលោកប្រធានមេត្តា បង្គាប់អោយមានវិធានការការពារតាមការស្នើសុំនេះ ដោយអនុលោមតាមនីតិវិធីច្បាប់និងដោយក្តីអនុគ្រោះ។

សូមលោកប្រធានមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៩

ហត្ថលេខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី ម៉ុច សុវណ្ណារី